# គណកម្មការទាំង៤ នៃ‹មូលនិធីឃុំសង្កាត់គំរូកម្ពុជា›

ក្រោមការគ្រប់គ្រងរបស់គណកម្មការនាយក ‹គណកម្មាធិការប្រតិបត្តិ-Executive commission›បង្កើតឡើងសម្រាប់ រៀបគម្រោងប្រចាំឆ្នាំ កំណត់កាលបរិច្ឆេត នឹងតាមដានការវិវត្តន៍ រហូតដល់ធ្វើការបានសម្រេច ។

គម្រោងដែលបានគិតរួចហើយ ត្រូវដាក់ជូន‹នាយកប្រតិបត្តិ› ជាអ្នកយកទៅអនុវត្តន៍។

គណកម្មកានាយកមានតួរនាទី តាមដានការអនុវត្តន៍គម្រោងនានាដែលខ្លួនបានដាក់ឱ្យ‹នាយកប្រតិបត្តិ›ធ្វើ ផ្ដល់ការពិគ្រោះយោបល់ វាយតម្លៃលើកាងារដែលបានធ្វើ សម្តែងការកោតសសើរ លើកទឹកចិត្តនៅពេលបានលទ្ធផលល្អប្រសើរ ឬក៏ធ្វើការស្ដីបន្ទោសក្នុងករណីដែលការអនុវត្តន៍ប្រាស់ចាកពីគោលការសីលធម៌ ឬមិនបានធ្វើតាមបទបញ្ជា។

គណកម្មាធិការមូលនិធីទាំង៤មានៈ

១-គណកម្មាធិការរៃអង្គាស - Fund raising commission

២-គណកម្មាធិការអភិវឌ្ឍន៍ធនាគារម្ហូបអាហារសម្រាប់ឃុំសង្កាត់ - Food bank commission

៣-គណកម្មាធិការថែរក្សាសុខភាពប្រជាពលរដ្ឋក្នុងឃុំសង្កាត់ - Health commision

៤-គណកម្មាធិការអភិវឌ្ឍន៍វិស័យទំនាក់ទំនងសាធារណ - Communication commission

## ១-គណកម្មាធិការរៃអង្គាស – Fund raising commission

<u>រចនាសម្ព័ន្ធ</u>

តែងតាំងសមាជិកគណកម្មការនាយកម្នាក់ ជា‹ប្រធានគណកម្មការរៃអង្គាស›

តែងតាំងគណកម្មការជំនាញ៤រូបទៀត មានដំណែងជា‹អនុប្រធានគណកម្មការរៃអង្គាស› មានភារកិច្ចជួយរៀបចំគម្រោងកម្មវិធីរៃអង្គាស ពេញមួយឆ្នាំ ដែលមានៈ

ក-<u>អនុប្រធានខាង‹កម្មវិធីវិភាគទានប្រចាំខែ›</u>

- មានគោលការរកសមាជិកដែលបង់វិភាគទានប្រចាំខែ ឱ្យបាន១,០០០នាក់ក្នុងរយៈពេល៣ខែ
- មានគោលការ តាមដានការវិវត្តន៍ ដាក់ធនធានបញ្ចូលក្នុងគណនេយ្យ ដើម្បីសម្រួលការត្រួតពិនិត្យ
- មានគោលការបង្ហាញថានាតម្លាភាពឱ្យបានគ្រប់គ្រាន់ជាមួយម្ចាស់វិភាគទាន

ខ-<u>អនុប្រធានខាង‹កម្មវិធីបុណ្យសាសនា›</u>

- មានគោលការធ្វើបុណ្យផ្កា ៣ ដងក្នុងមួយឆ្នាំ នៅវត្តផ្សេងគ្នាក្នុងឡូវែល (វត្ត១ មួយឆ្នាំម្តង)
- មានគម្រោងជួយធ្វើបុណ្យ នៅវត្តក្នុង‹ឃុំសង្កាត់គំរូ›នៅកម្ពុជា រកជំនួយបន្ថែមនៅក្នុងស្រុក
- មានគោលការបង្ហាញតម្លាភាពឱ្យបានគ្រប់គ្រាន់ជូនម្ចាស់ជំនួយ

គ-<u>អនុប្រធានខាង‹កម្មវិធីរាត្រីសមោសរ›</u>

- មានគម្រោងនាំមេឃុំថ្មី មកធ្វើការឃោសនាបង្ហាញខ្លួន-បង្ហាញឃុំសង្កាត់ ក្នុងរាត្រីសមោស
- រៀបធ្វើពិធីបុណ្យនានា ដោយមានក្រុមសិល្បៈចូលរួម ឬមានបញ្ចាំងកុន

- រៀបគម្រោងម្តងៗបន្តរទៅ៥កន្លែងផ្សេងទៀត ក្នុងតំបន់ដែលមានមិត្ររបស់មូលនិធិនៅទីនោះ
- មានគោលការបង្ហាញតម្លាភាពឱ្យបានគ្រប់គ្រាន់ជូនម្ចាស់ជំនួយ

ឃ-<u>អនុប្រធានខាង‹កម្មវិធីផ្សព្វផ្សាយពាណិជ្ជកម្ម›</u>

- គោលការធ្វើសៀវភៅផ្សាយពាណិជ្ជកម្ម នៅពេលមានពិធីបុណ្យអ្វីមួយ
- គោលការ រកកម្រៃដោយលក់របស់អនុស្សាវរីយ៍ មកពី‹ឃុំសង្កាត់គំរូ›
- រៀបគម្រោងធ្វើការតាំងពិពណ៌ពី‹ការវិវត្តន៍ឃុំសង្កាត់គំរូ› ដើម្បីគំនិតថ្មីសម្រាប់រកទិស ជួយឃុំសង្កាត់យើងជាបន្តទៅមុខទៀត។
- មានគោលការបង្ហាញតម្លាភាពឱ្យបានគ្រប់គ្រាន់ជូនម្ចាស់ជំនួយ។